# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

និយ័តករទូរគមនាគមន៍កម្ពុជា

លេខ: ១០៨៦/២៧...ន.ទ.ក.

## សេចក្តីជូនដំណឹង
## ស្តីពី
## ការបើកដំណើរការសាជាថ្មីនូវលេខទូរស័ព្ទចល័ត ដែលត្រូវបានបញ្ឈប់ដំណើរការ និង ការកំណត់រយៈពេលនៃការរក្សាទុកទឹកប្រាក់ក្នុងគណនីគោល ក្រោយពេលផុតសុពលភាពប្រើប្រាស់

និយ័តករទូរគមនាគមន៍កម្ពុជា (ន.ទ.ក.) សូមជម្រាបជូនដល់សាធារណជនទាំងអស់ជ្រាបថា ដើម្បីធានាការប្រើប្រាស់សេវាទូរស័ព្ទឱ្យមានប្រសិទ្ធិភាព និងការពារផលប្រយោជន៍របស់អ្នកប្រើប្រាស់ ន.ទ.ក. បានតម្រូវឱ្យប្រតិបត្តិករទូរស័ព្ទចល័ត អនុវត្តចាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ២០២៦ ដូចខាងក្រោម÷

១- អ្នកប្រើប្រាស់សេវាទូរស័ព្ទចល័ត អាចបើកដំណើរការឡើងវិញនូវលេខទូរស័ព្ទចល័តរបស់ខ្លួនទាំងឡាយណា ដែលមានរយៈពេលផុតសុពលភាពនៃទឹកប្រាក់ក្នុងគណនីគោល មិនលើសពី ១៨០ (មួយរយប៉ែតសិប) ថ្ងៃ ដោយគ្រាន់តែបញ្ចូលទឹកប្រាក់ទៅក្នុងគណនីគោល និងមិនតម្រូវឱ្យអ្នកប្រើប្រាស់ធ្វើការចុះឈ្មោះសាជាថ្មីនៅទីតាំងផ្ទាល់របស់ក្រុមហ៊ុន ឬសាខាក្រុមហ៊ុនឡើយ។

២- ប្រតិបត្តិករទូរស័ព្ទចល័តត្រូវរក្សាទុកទឹកប្រាក់ក្នុងគណនីគោលរបស់លេខទូរស័ព្ទចល័ត សម្រាប់រយៈពេល១៨០(មួយរយប៉ែតសិប) ថ្ងៃ ក្រោយពេលផុតសុពលភាពនៃទឹកប្រាក់ក្នុងគណនីគោល។ ក្នុងរយៈពេល ១៨០ (មួយរយប៉ែតសិប) ថ្ងៃ នេះ អ្នកប្រើប្រាស់នឹងទទួលបានទឹកប្រាក់ក្នុងគណនីគោល ដែលមាននៅសល់ចុងក្រោយត្រឡប់មកវិញ ប្រសិនបើអ្នកប្រើប្រាស់ធ្វើការបញ្ចូលទឹកប្រាក់ក្នុងគណនីគោលរួច។

៣- មុនផុតរយៈពេល ១៨០ (មួយរយប៉ែតសិប)ថ្ងៃ នៃការរក្សាទុកទឹកប្រាក់ក្នុងគណនីគោលរបស់លេខទូរស័ព្ទចល័ត ប្រតិបត្តិករទូរស័ព្ទចល័តត្រូវរំលឹកដល់អ្នកប្រើប្រាស់ តាមរយៈសារខ្លី(SMS) យ៉ាងតិច ២(ពីរ) ដង និងកម្មវិធីទូរស័ព្ទរបស់ប្រតិបត្តិករទូរស័ព្ទចល័ត ក្នុងពេលសមស្រប ដើម្បីឱ្យអ្នកប្រើប្រាស់បានដឹងជាមុនអំពីកាលបរិច្ឆេទនៃការបញ្ឈប់ដំណើរការទាំងស្រុង និងការទទួលបានទឹកប្រាក់ក្នុងគណនីគោល ដែលមាននៅសល់ចុងក្រោយត្រឡប់មកវិញ ប្រសិនបើអ្នកប្រើប្រាស់ធ្វើការបញ្ចូលទឹកប្រាក់ក្នុងគណនីគោលរួច។

ករណីមានភាពមិនប្រក្រតីណាមួយពាក់ព័ន្ធនឹងការប្រើប្រាស់សេវាទូរគមនាគមន៍ អ្នកប្រើប្រាស់សេវាទូរគមនាគមន៍ទាំងអស់ អាចរាយការណ៍មក ន.ទ.ក. តាមរយៈលេខទូរស័ព្ទ **៦៧៨៩** នៅរៀងរាល់ម៉ោងធ្វើការ ឬផ្ញើសារមកកាន់អ៊ីម៉ែល info@trc.gov.kh ឬតាមរយៈទំព័រហ្វេសប៊ុកផ្លូវការរបស់ ន.ទ.ក. "**និយ័តករទូរគមនាគមន៍កម្ពុជា - Telecommunication Regulator of Cambodia**"។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមសាធារណជនទាំងអស់ជ្រាបជាព័ត៌មាន។

ថ្ងៃចន្ទ ៣កើត ខែបុស្ស ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩

រាជធានីភ្នំពេញ ថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០២៥